# គោលការណ៍ជាមូលដ្ឋាន ស្តីពីការប្រើប្រាស់កម្លាំង និង អាវុធ ដោយមន្ត្រីប្រតិបត្តិច្បាប់

## Basic Principles on the Use of Force and Firearms by Law Enforcement Officials



# គោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់

## Basic Principles on the Use of Force and Firearms by Law Enforcement Officials

បានអនុម័តដោយសន្និបាតអង្គការសហប្រជាជាតិលើកទីប្រាំបីស្តីពីការបង្ការបទឧក្រិដ្ឋ និងការប្រព្រឹត្តលើជនល្មើស
ដែលសន្និបាតនេះបានប្រារព្ធធ្វើនៅឯទីក្រុងហាវ៉ាណា ប្រទេសគុយបា ចាប់ថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា១៩៩០ ។
Adopted by the Eighth United Nations Congress on the Prevention of Crime and the Treatment of Offenders, Havana, Cuba, 27 August to 7 September 1990.

*ដោយហេតុថា* ការងាររបស់មន្ត្រីប្រតិបត្តិច្បាប់* គឺជាសេវាសង្គមដ៏សំខាន់បំផុតមួយ ដូច្នេះហើយចាំបាច់ត្រូវរក្សា និងនៅពេលណាដែលចាំបាច់ ត្រូវកែលំអដល់ស្ថានភាព និងលក្ខខណ្ឌការងាររបស់មន្ត្រីទាំងនេះ ។

*ដោយហេតុថា* គេត្រូវតែយល់ឃើញថា ការគំរាមកំហែងមកលើជីវិត និងសុវត្ថិភាពរបស់មន្ត្រីប្រតិបត្តិច្បាប់ គឺជាការគំរាមកំហែងដល់ស្ថិរភាពសង្គមទាំងមូល ។

*ដោយហេតុថា* មន្ត្រីប្រតិបត្តិច្បាប់ មានតួនាទីដ៏សំខាន់មួយក្នុងការការពារសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់មនុស្ស ដូចដែលបានធានានៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងបានប្រកាសជាថ្មីនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

*ដោយហេតុថា* បញ្ញត្តិជាបទដ្ឋានអប្បបរិមាសំរាប់គ្រប់គ្រងអ្នកទោសមានចែង ពីកាលៈទេសៈដែលមន្ត្រីពន្ធនាគារអាចប្រើកម្លាំងបាន នៅក្នុងពេលបំពេញភារៈកិច្ចរបស់ខ្លួន ។

*ដោយហេតុថា* មាត្រា៣ នៃក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់ចែងថា មន្ត្រីប្រតិបត្តិច្បាប់អាចប្រើកម្លាំងបានតែនៅកាលៈទេសៈដែលចាំបាច់បំផុត ហើយត្រូវកំរិតត្រឹមតែក្នុងវង្វង់នៃការបំពេញបេសកកម្មតែប៉ុណ្ណោះ ។

---

* អនុលោមតាមសេចក្តីអធិប្បាយក្នុងមាត្រា១ ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់ ពាក្យថា" មន្ត្រីប្រតិបត្តិច្បាប់" សំដៅដល់មន្ត្រីទាំងឡាយ ដែលទទួលបន្ទុកខាងការអនុវត្តច្បាប់ ទោះជាតែងតាំង ឬជ្រើសតាំងក៏ដោយ ដែលមន្ត្រីទាំងនេះប្រើប្រាស់អំណាចនគរបាល ជាពិសេស អំណោចក្នុងការចាប់ខ្លួន ឬឃុំខ្លួន ។ នៅក្នុងប្រទេសទាំងឡាយណា ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាទូទៅ ឬមិនទូទៅក៏ដោយ ឬដោយកំលាំងសន្តិសុខរដ្ឋ និយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ត្រូវរួមបញ្ចូលទាំងមន្ត្រី ដែលបំរើសេវាកម្មនេះផងដែរ ។

*ដោយហេតុថា* ក្នុងកិច្ចប្រជុំរៀបចំសន្និបាតរបស់អង្គការសហប្រជាជាតិលើកទីប្រាំពីរ ស្តីអំពីការទប់ស្កាត់បទល្មើស និងការគ្រប់គ្រងជនល្មើសដែលធ្វើនៅទីក្រុងវ៉ារីនណាប្រទេសអ៊ីតាលី បានឯកភាពគ្នាលើកគន្លងដែលត្រូវយកទៅពិចារណានៅក្នុងការងារជាបន្តបន្ទាប់ស្តីពីការកំហិតនៃការប្រើកម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ។

*ដោយហេតុថា* សន្និបាតលើកទីប្រាំពីរ ក្នុងចំណោមចំណុចផ្សេងៗនៃសេចក្តីសំរេចចិត្តលេខ១៤របស់ខ្លួន បញ្ជាក់ថា ការប្រើកម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ត្រូវធ្វើឱ្យបានសមស្របទៅនឹងការគោរពសិទ្ធិមនុស្ស ។

*ដោយហេតុថា* នៅក្នុងសេចក្តីសំរេចចិត្តលេខ១៩៨៦/១០ ជំពូកប្រាំបួន (IX) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៨៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម បានអញ្ជើញរដ្ឋជាសមាជិកទាំងឡាយ ឱ្យផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការអនុវត្តន៍គោលការណ៍ជាមូលដ្ឋានស្តីពីការប្រើកម្លាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ និង ក្នុងចំណោមចំណុចផ្សេងៗនៃសេចក្តីសំរេចចិត្តលេខ៤១/១៤៩ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ ១៩៨៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ បានស្វាគមន៍សេចក្តីស្នើយោបល់ដែលក្រុមប្រឹក្សានេះបានធ្វើឡើង ។

*ដោយហេតុថា* ការគិតដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គេម្នាក់ៗ ជាការត្រឹមត្រូវនោះ មន្ត្រីប្រតិបត្តិច្បាប់គួរធ្វើការពិចារណាអំពីតួនាទីរបស់ខ្លួន ចំពោះការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ចំពោះការការពារសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់មនុស្ស ចំពោះការទទួលខុសត្រូវរបស់ពួកគេក្នុងការរក្សាសុវត្ថិភាពសាធារណៈ និងសន្តិភាពសង្គម និងចំពោះសារសំខាន់នៃ លក្ខណៈសម្បត្តិការងារ ការបណ្តុះបណ្តាល និងចរិយាមាយាទរបស់គេ ។

គោលការណ៍ជាមូលដ្ឋានដូចមានចែងខាងក្រោម ដែលត្រូវបានបង្កើតឡើង ដើម្បីជួយដល់រដ្ឋជាសមាជិកទាំងឡាយក្នុងការងាររបស់ខ្លួន ក្នុងការធានា និងលើកស្ទួយតួនាទីត្រឹមត្រូវរបស់មន្ត្រីប្រតិបត្តិច្បាប់នោះ គប្បីយកទៅពិចារណា និងគោរព ដោយរដ្ឋាភិបាលនានា ក្នុងក្របខ័ណ្ឌនៃការតាក់តែងច្បាប់ជាតិ និងការអនុវត្តន៍របស់ខ្លួន ហើយត្រូវផ្សព្វផ្សាយដល់មន្ត្រីប្រតិបត្តិច្បាប់ ព្រមទាំងអ្នកដទៃទៀតដូចជា ចៅក្រម ព្រះរាជអាជ្ញា អ្នកច្បាប់ សមាជិកនៃអង្គការនីតិប្រតិបត្តិ និងអង្គការនីតិបញ្ញត្តិ ហើយនិងសាធារណៈជន ។

# បទបញ្ញត្តិទូទៅ

១. រដ្ឋាភិបាល និងស្ថាប័នប្រតិបត្តិច្បាប់នានា ត្រូវអនុម័តនិងអនុវត្តវិធាន និងបទប្បញ្ញត្តិផ្សេងៗស្តីពីការប្រើប្រាស់កម្លាំង និងអាវុធចំពោះមនុស្សដោយមន្ត្រីប្រតិបត្តិច្បាប់ ។ ក្នុងការបង្កើតវិធាននិងបទប្បញ្ញត្តិផ្សេងៗ រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកប្រតិបត្តិច្បាប់ត្រូវរក្សាបញ្ហាសីលធម៌ ទាក់ទងទៅនឹងការប្រើប្រាស់កម្លាំង និងអាវុធឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យជាប់ជានិច្ច ។

២. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកប្រតិបត្តិច្បាប់ គួរបង្កើតជាមធ្យោបាយឱ្យបានទូលំទូលាយបំផុត ហើយបំពាក់អាវុធ និងគ្រាប់រំសេវគ្រប់ប្រភេទដល់មន្ត្រីប្រតិបត្តិច្បាប់ ដែលនឹងអនុញ្ញាតឱ្យមានការប្រើប្រាស់កម្លាំង និងអាវុធខុសៗគ្នា ។ ការនេះគួររួមបញ្ចូលទាំងការបង្កើតអាវុធដែលមិនបង្កគ្រោះថ្នាក់ដល់ជីវិត សំរាប់ប្រើប្រាស់ក្នុងស្ថានភាពសមស្រប ក្នុងគោលបំណងដាក់កំហិតថែមទៀតដល់ការប្រើប្រាស់មធ្យោបាយផ្សេងៗ ដែលអាចបង្កឱ្យមានរបួស ឬគ្រោះថ្នាក់ដល់ជីវិតមនុស្ស ក្នុងគោលបំណងដូចគ្នានេះដែរ គួរតែមានលទ្ធភាពបំពាក់ឧបករណ៍ការពារខ្លួន ដូចជា ខែល មួកការពារគ្រោះថ្នាក់ អាវកាក់ការពារគ្រាប់ និងមធ្យោបាយដឹកជញ្ជូនដែលមានប្រដាប់ការពារគ្រាប់ ដល់មន្ត្រីប្រតិបត្តិច្បាប់ ដើម្បីកាត់បន្ថយសេចក្តីត្រូវការក្នុងការប្រើប្រាស់អាវុធគ្រប់ប្រភេទ ។

៣. ការបង្កើត និងការចែកចាយឱ្យប្រើប្រាស់អាវុធដែលមិនបង្កគ្រោះថ្នាក់ដល់ជីវិត គប្បីវាយតម្លៃឱ្យបានហ្មត់ចត់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ឱ្យបានជាអប្បបរិមាដល់មនុស្សដែលមិនមានជាប់ពាក់ព័ន្ធ ហើយការប្រើប្រាស់អាវុធបែបនេះ គប្បីត្រូវត្រួតពិនិត្យឱ្យបានហ្មត់ចត់ ។

៤. ក្នុងពេលបំពេញភារកិច្ច មន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ត្រូវប្រើប្រាស់មធ្យោបាយអហឹង្សាទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន មុននឹងឈានដល់ការប្រើប្រាស់កម្លាំង និងអាវុធ ។ មន្ត្រីប្រតិបត្តិច្បាប់ អាចប្រើប្រាស់កម្លាំង និងអាវុធបាន លុះត្រាតែមធ្យោបាយផ្សេងទៀតពុំមានប្រសិទ្ធិភាព ឬក៏មិនមានការធានាណាមួយថាអាចសម្រេចលទ្ធផលដែលបានគ្រោងទុកនោះ ។

៥. នៅពេលណាដែលមិនអាចជៀសវាងបានក្នុងការប្រើកម្លាំង និងអាវុធស្របច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវ :

"ក" ដាក់កំហិតក្នុងការប្រើប្រាស់កម្លាំង និងអាវុធបែបនោះ ត្រូវឱ្យមានសមាមាត្រទៅនឹងស្ថានទម្ងន់នៃបទល្មើស និងគោលដៅត្រឹមត្រូវតាមច្បាប់ដែលត្រូវធ្វើឱ្យបានសំរេច ។

"ខ" កាត់បន្ថយនូវការខូចខាត និងការរងរបួសជាអប្បបរិមា ហើយគោរព និងការពារជីវិតមនុស្ស

"គ" ធានាថាការជួយជ្រោមជ្រែង និងជំនួយផ្នែកពេទ្យ ត្រូវបានផ្តល់ជូនយ៉ាងឆាប់បំផុតដល់មនុស្សដែលរងរបួស ឬរងការប៉ះទង្គិច ។

"ឃ" ធានាថា សាច់ញាតិ ឬមិត្តភ័ក្រជិតស្និទរបស់ជនរងរបួស ឬរងការប៉ះទង្គិច ត្រូវបានផ្តល់ដំណឹងយ៉ាងឆាប់បំផុត ។

៦. ទីណាដែលមានការរងរបួស ឬការស្លាប់ដែលបណ្តាលមកពីការប្រើប្រាស់កម្លាំងនិងអាវុធ ដោយមន្ត្រីប្រតិបត្តិច្បាប់ គេត្រូវរាយការណ៍អំពីហេតុការណ៍នោះភ្លាម១ ដល់មន្ត្រីថ្នាក់លើរបស់ខ្លួនស្របតាមគោលការណ៍ទី២២ ។

៧. រដ្ឋាភិបាលត្រូវធានាថា ការប្រើប្រាស់កម្លាំង និងអាវុធតាមតែអំពើចិត្ត ឬដោយរំលោភដោយមន្ត្រីប្រតិបត្តិច្បាប់ ត្រូវផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់របស់ខ្លួន ។

៨. មិនអាចយកកាលៈទេសៈលើកលែងខ្លះ ដូចជាអស្ថិរភាពនយោបាយផ្ទៃក្នុង ឬភាពអាសន្នជាទូទៅផ្សេងទៀត មកសំអាងដើម្បីបង្ហាញពីភាពសមហេតុសមផល នៃការប្រព្រឹត្តខុសពីគោលការណ៍ជាមូលដ្ឋាននេះបានឡើយ ។

## បញ្ញត្តិពិសេស

៩. មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវប្រើអាវុធបំពានទៅលើមនុស្សឡើយ លើកលែងតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដែលនាំឱ្យមានការស្លាប់ ឬរបួសធ្ងន់ធ្ងរដែលជិតនឹងកើតឡើង ដើម្បីបង្ការការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរណាមួយដែលពាក់ព័ន្ធនឹងការគំរាមកំហែងដល់អាយុជីវិត ដើម្បីចាប់ជនណាម្នាក់ដែលនឹងនាំមកនូវគ្រោះថ្នាក់ ឬប្រឆាំងតដៃនឹងអាជ្ញាធររបស់ខ្លួន ឬដើម្បីបង្ការការរត់គេចរបស់គេ ហើយនិងនៅពេលណាដែលមធ្យោបាយធូរស្រាលទាំងឡាយមិនអាចមានគ្រប់គ្រាន់ដើម្បីធ្វើឱ្យគោលដៅទាំងនេះសំរេចបានតែប៉ុណ្ណោះ។ ទោះនៅក្នុងព្រឹត្តិការណ៍យ៉ាងណាក៏ដោយ ការប្រើប្រាស់អាវុធសម្លាប់ដោយចេតនា អាចធ្វើទៅបាន តែនៅពេលណាដែលមានការចាំបាច់បំផុត ហើយនិងមិនអាចជៀសវាងបាន ដើម្បីការពារអាយុជីវិតមនុស្សតែប៉ុណ្ណោះ ។

១០. ក្នុងកាលៈទេសៈទាំងឡាយណាដែលមានចែងក្នុងគោលការណ៍ទី៩ មន្ត្រីប្រតិបត្តិច្បាប់ត្រូវធ្វើខ្លួនឱ្យស្របទៅតាមនោះ ហើយត្រូវផ្តល់ការព្រមានឱ្យបានច្បាស់អំពីគោលបំណងរបស់ខ្លួនថានឹងប្រើប្រាស់អាវុធ ដោយទុកពេលវេលាគ្រប់គ្រាន់ ដើម្បីឱ្យគេប្រតិបត្តិតាមការព្រមាននោះ លើកលែងតែការធ្វើបែបនេះ នឹងបណ្តាលឱ្យមន្ត្រីប្រតិបត្តិ

ច្បាប់នោះស្ថិតក្នុងសភាពគ្រោះថ្នាក់ ឬបង្កើតឱ្យមានគ្រោះថ្នាក់ដល់ស្លាប់ ឬអន្តរាយធ្ងន់ធ្ងរដល់អ្នកដទៃ ឬយល់ឃើញថា ជាការធ្វើមិនសមស្រប ឬឥតប្រយោជន៍ក្នុងកាលៈទេសៈដែលឧប្បត្តិហេតុនោះបានកើតឡើង ។

១១. វិធាន និងបទបញ្ជាស្តីពីការប្រើប្រាស់អាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ គប្បីរាប់បញ្ចូលទាំងគោលការណ៍ណែនាំដែល :

"ក" បញ្ជាក់ពីកាលៈទេសៈដែលមន្ត្រីប្រតិបត្តិច្បាប់ ត្រូវបានអនុញ្ញាតឱ្យកាន់អាវុធ ហើយកំណត់នូវប្រភេទអាវុធនិងគ្រាប់រំសេវដែលបានអនុញ្ញាតឱ្យកាន់

"ខ" ធានាថា អាវុធត្រូវយកទៅប្រើតែក្នុងកាលៈទេសៈសមស្រប និងក្នុងលក្ខណៈអាចកាត់បន្ថយការប្រថុយនឹងភាពអន្តរាយដែលមិនចាំបាច់តែប៉ុណ្ណោះ

"គ" ហាមឃាត់ការប្រើប្រាស់អាវុធនិងគ្រាប់រំសេវ ដែលបណ្តាលឱ្យមានរបួស ឬធ្វើឱ្យមានគ្រោះថ្នាក់ ដោយមិនសមហេតុផល

"ឃ" ដាក់កំរិតការត្រួតពិនិត្យ ការស្តុកទុក និងការចែកចាយអាវុធ រួមទាំងទម្រង់ការសំរាប់ធានាថា មន្ត្រីប្រតិបត្តិច្បាប់ទទួលខុសត្រូវចំពោះអាវុធ និងគ្រាប់រំសេវ ដែលបានចែកចាយទៅឱ្យខ្លួន

"ង" ត្រូវផ្តល់ការព្រមានជាមុនសិន ហើយជាការប្រសើ ត្រូវប្រាប់ថា នៅពេលណាដែលយើងត្រូវបាញ់

"ច" ចែងពីប្រព័ន្ធមួយស្តីពីការធ្វើរបាយការណ៍ នៅពេលណាដែលមន្ត្រីប្រតិបត្តិច្បាប់ប្រើប្រាស់អាវុធនៅក្នុងការបំពេញភារៈកិច្ចរបស់ខ្លួន។

## ការល្បាតមើលលើការប្រជុំគ្នាមិនស្របច្បាប់

១២. ដោយហេតុថា មនុស្សគ្រប់រូបត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការប្រជុំដោយសន្តិវិធី និងស្របច្បាប់ស្របតាមគោលការណ៍ដែលចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស និងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយនោះ រដ្ឋាភិបាល ស្ថាប័ន និងមន្ត្រីប្រតិបត្តិច្បាប់ត្រូវទទួលស្គាល់ថាកម្លាំង និងអាវុធអាចយកទៅប្រើប្រាស់បាន លុះត្រាតែការប្រើប្រាស់នោះស្របទៅតាមគោលការណ៍ទី ១៣ និង ១៤ តែប៉ុណ្ណោះ ។

១៣. នៅក្នុងការបំបែកការប្រជុំដែលមិនស្របច្បាប់និងដែលមិនប្រើអំពើហឹង្សា មន្ត្រីប្រតិបត្តិច្បាប់ ត្រូវធ្វើយ៉ាងណា ជៀសវាងការប្រើកម្លាំង ឬបើនៅទីណាដែលមិនអាចអនុវត្តបាន ត្រូវកំហិតការប្រើកម្លាំងបែបនោះ កុំឱ្យលើសពីការចាំបាច់ជាអប្បបរិមា។

១៤. នៅក្នុងការបំបែកការប្រជុំដែលមានអំពើហិង្សា មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់អាវុធបានតែនៅពេលណាដែលមធ្យោបាយធ្វើឱ្យមានគ្រោះថ្នាក់តិចនោះមិនអាចអនុវត្តទៅបាន ហើយការប្រើប្រាស់អាវុធនេះមិនត្រូវឱ្យលើសពីការចាំបាច់ជាអប្បបរិមាឡើយ ។ មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវប្រើប្រាស់អាវុធនៅក្នុងករណីបែបនេះទេ លើកលែងតែស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងគោលការណ៍ទី ៩ ។

## ការល្បាតមើលជនដែលស្ថិតនៅក្នុងការឃុំគ្រង ឬឃុំឃាំង

១៥. មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវប្រើប្រាស់កម្លាំងទេក្នុងការទំនាក់ទំនងរបស់ខ្លួនជាមួយនឹងជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំង លើកលែងតែក្នុងករណីដែលចាំបាច់តឹងរឹងបំផុត ដើម្បីរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់នៅក្នុងស្ថាប័ន ឬនៅពេលណាដែលមានការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

១៦. មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវប្រើប្រាស់អាវុធទេក្នុងការទំនាក់ទំនងរបស់ខ្លួន ជាមួយនឹងជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំង លើកលែងតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដល់សេចក្តីស្លាប់ ឬធ្វើឱ្យមានរបួសធ្ងន់ធ្ងរ ឬនៅពេលដែលចាំបាច់បំផុត ដើម្បីបង្ការការរត់គេចនៃជនដែលស្ថិតនៅក្រោមការឃុំគ្រង ឬឃុំឃាំងដែលជាហេតុនាំមកនូវគ្រោះថ្នាក់ ដូចបានរៀបរាប់នៅក្នុងគោលការណ៍ទី ៩ ។

១៧. គោលការណ៍ដូចដែលមានពីខាងដើម មិនធ្វើឱ្យខូចប្រយោជន៍ដល់សិទ្ធិ ភារកិច្ចនិងការទទួលខុសត្រូវរបស់មន្ត្រីពន្ធនាគារ ដូចមានចែងនៅក្នុងបញ្ញត្តិជាបទដ្ឋានអប្បបរិមាសំរាប់គ្រប់គ្រងអ្នកទោស ជាពិសេសត្រង់ប្រការ ៣៣, ៣៤ និង ៥៤ ឡើយ ។

## លក្ខណៈសម្បត្តិ ការហ្វឹកហ្វឺន និងការឱ្យយោបល់

១៨. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវធានាថា មន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ ត្រូវបានជ្រើសរើសឡើងតាមនីតិវិធីជ្រើសរើសដ៏ត្រឹមត្រូវ មានសីលធម៌សមរម្យ មានកាយសម្បទាមាំមួន និងមានចិត្តរឹងប៉ឹងដើម្បីអនុវត្តការងាររបស់គេឱ្យមានប្រសិទ្ធិភាព និងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈជាបន្តបន្ទាប់ និង យ៉ាងហ្មត់ចត់។ កាយសម្បទារឹងមាំ ចិត្តរឹងប៉ឹង និងសីលធម៌សមរម្យជានិច្ចក្នុងការបំពេញភារៈកិច្ច របស់មន្ត្រីប្រតិបត្តិច្បាប់ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យឱ្យបានទៀង ទាត់តាមកាលកំណត់ ។

១៩. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវធានាថា មន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ ត្រូវបានទទួលការហ្វឹកហ្វឺននិងត្រូវបានទទួលការសាកល្បង ស្របទៅនឹងបទដ្ឋានជំនាញក្នុងការប្រើប្រាស់កម្លាំង។ មន្ត្រីប្រតិបត្តិច្បាប់ទាំងឡាយដែលគេតម្រូវឱ្យកាន់អាវុធ នឹងត្រូវទទួលការអនុញ្ញាតឱ្យកាន់បានតែនៅពេលណាដែលបានបញ្ចប់ការហ្វឹកហ្វឺនពិសេសក្នុងការប្រើប្រាស់អាវុធទាំងនេះជាមុនសិនប៉ុណ្ណោះ ។

២០. ក្នុងការហ្វឹកហ្វឺនដល់មន្ត្រីប្រតិបត្តិច្បាប់ទាំងឡាយ រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាក្រមសីលធម៌របស់នគរបាល និងបញ្ហាសិទ្ធិមនុស្ស ជាពិសេសនៅក្នុងដំណាក់ការស៊ើបអង្កេត ចំពោះមធ្យោបាយជំនួសការប្រើប្រាស់កម្លាំងនិងអាវុធ រួមទាំងដំណោះស្រាយជម្លោះដោយសន្តិវិធី ការយល់ដឹងអំពីឥរិយាបទនៃការប្រព្រឹត្តរបស់ហ្វូងមនុស្ស និងវិធីសាស្ត្របញ្ចុះបញ្ចូល ការចចារ និងការសម្រុះសម្រួល ព្រមទាំងមធ្យោបាយបច្ចេកទេសផង ក្នុងទស្សនៈមួយដើម្បីកំហិតការប្រើប្រាស់កម្លាំងនិងអាវុធ។ ស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ គប្បីពិនិត្យមើលកម្មវិធីហ្វឹកហ្វឺន និងនីតិវិធីប្រតិបត្តិការរបស់ខ្លួនឡើងវិញ ដោយយោងទៅតាមឧប្បត្តិហេតុនីមួយៗ។

២១. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវផ្តល់យោបល់យ៉ាងជាក់ច្បាស់ដល់មន្ត្រីប្រតិបត្តិច្បាប់ទាំងឡាយណាដែលមានការពាក់ព័ន្ធក្នុងស្ថានភាព ដែលតំរូវឱ្យមានការប្រើប្រាស់កម្លាំង និងអាវុធ ។

## នីតិវិធីក្នុងការធ្វើរបាយការណ៍ និងការពិនិត្យមើលឡើងវិញ

២២. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវបង្កើតនីតិវិធីក្នុងការធ្វើរបាយការណ៍ និងការពិនិត្យមើលឡើងវិញឱ្យមានប្រសិទ្ធិភាព ចំពោះឧប្បត្តិហេតុទាំងអស់ដូចមានរៀបរាប់នៅក្នុងគោលការណ៍ទី៦ និង ១១ "ច" ។ ចំពោះឧប្បត្តិហេតុដែលរាយការណ៍ស្របតាមគោលការណ៍ទាំងនេះ រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវធានាឱ្យមានរបៀបដ៏មានប្រសិទ្ធិភាពមួយក្នុងការត្រួតពិនិត្យឡើងវិញ ព្រមទាំងធានាថាមានអាជ្ញាធរឯករាជ្យផ្នែករដ្ឋបាល និងផ្នែកអយ្យការដែលអាចអនុវត្តយុត្តាធិការតាមកាលៈទេសៈសមស្របនេះបាន។ ក្នុងករណីដែលមានស្លាប់ ឬរបួសធ្ងន់ ឬផលវិបាកធ្ងន់ធ្ងរ ត្រូវធ្វើរបាយការណ៍ពិស្តារមួយ ហើយបញ្ជូនជាប្រញាប់ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យមើលផ្នែករដ្ឋបាល និងគ្រប់គ្រងផ្នែកតុលាការ ។

២៣. ជនដែលទទួលរងគ្រោះពីការប្រើប្រាស់កម្លាំង និងអាវុធ ឬអ្នកតំណាងខាងច្បាប់របស់ខ្លួន ត្រូវមានលទ្ធភាពរកវិធីឯករាជ្យមួយ ក្នុងនោះរួមបញ្ចូលទាំងវិធីតាមផ្លូវតុលាការផង ។ នៅក្នុងព្រឹត្តិការណ៍ដែលជនទាំងនោះស្លាប់ បទបញ្ញត្តិនេះអាច អនុវត្តបានចំពោះមនុស្សដែលស្ថិតនៅក្នុងបន្ទុករបស់គេ ។

២៤. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវធានាថា មន្ត្រីថ្នាក់លើត្រូវចាប់ឱ្យទទួលខុសត្រូវ ប្រសិនបើគេដឹង ឬគួរតែបានដឹងថា មន្ត្រីប្រតិបត្តិច្បាប់ដែលនៅក្រោមបង្គាប់បញ្ជារបស់ខ្លួនកំពុង ឬបានប្រើប្រាស់កម្លាំង និងអាវុធមិនត្រឹមត្រូវតាមច្បាប់ ហើយមន្ត្រីថ្នាក់លើនោះ មិនបានចាត់វិធានការណ៍តាមអំណាចរបស់ខ្លួន ដើម្បីការពារ បង្ក្រាប ឬរាយការណ៍ អំពីការប្រើកម្លាំង និងអាវុធបែបនេះទេនោះ ។

២៥. រដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ ត្រូវធានាថា មិនត្រូវដាក់វិន័យ ឬដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌលើមន្ត្រីប្រតិបត្តិច្បាប់ណាដែលបដិសេធ មិនអនុវត្តតាមបទបញ្ជាឱ្យប្រើប្រាស់កម្លាំង និងអាវុធ ឬដែលរាយការណ៍អំពីការប្រើប្រាស់កម្លាំង និងអាវុធបែបនោះដោយមន្ត្រីដទៃៗទៀតឡើយ ព្រោះគេអនុវត្តស្របតាមបទវិន័យសំរាប់មន្ត្រីប្រតិបត្តិច្បាប់ និងគោលការណ៍ជាមូលដ្ឋានទាំងនេះ ។

២៦. ការគោរពតាមបទបញ្ជាថ្នាក់លើ មិនអាចធ្វើជាខែល ដើម្បីការពារខ្លួនបានទេ ប្រសិនបើមន្ត្រីប្រតិបត្តិច្បាប់នោះបានដឹងថា បទញ្ជាឱ្យប្រើប្រាស់កម្លាំង និងអាវុធ នឹងបណ្តាលឱ្យមានការស្លាប់ ឬរបួសធ្ងន់ធ្ងរដល់ជនណាម្នាក់នោះជាក់ស្តែងគឺមិនត្រឹមត្រូវតាមច្បាប់ ហើយថែមទាំងមានឱកាសសមល្មមនឹងបដិសេធមិនអនុវត្តតាមបញ្ជានោះបានទៀតផង ។ ទោះក្នុងករណីណាក៏ដោយ ក៏មន្ត្រីថ្នាក់លើដែលជាអ្នកចេញបញ្ជាមិនត្រឹមត្រូវតាមច្បាប់នោះ ត្រូវទទួលខុសត្រូវផងដែរ ។

~~~~~~~~~
~~~~~~~~~